# ព្រឹត្តិបត្រព័ត៌មាន

## សាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន ពាមជីកង

លេខ០៦ ខែមិថុនា ឆ្នាំ២០២៤



ហ្វេសប៊ុកផេក៖ វិទ្យាល័យ ហ៊ុនសែន ពាមជីកងជំនាន់ថ្មី
លេខទូរសព្ទ៖ 096 7273 921/ 087 609 156
គេហទំព័រ www.pck.ngs.edu.kh
អ៊ីម៉ែល៖ ngspckhighschool@gmail.com


### មាតិកា


- សកម្មភាពធ្វើប្រេងដូងត្រជាក់របស់ប្អូនៗក្នុងក្លឹបវិទ្យាសាស្រ្ត
- កម្មវិធីល្បែងយល់ពីជំនាញស្ទែម
- កម្លាំងជំនាញ នៃអធិការដ្ឋាននគរបាលស្រុកកងមាស បានបន្តវិធានការចុះផ្សព្វផ្សាយស្តីពី ច្បាប់ចរាចរណ៍ផ្លូវគោក, ច្បាប់គ្រឿងញៀន វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបក្មេងទំនើង ដល់សិស្សានុសិស្ស
- ប្រឡងប្រចាំខែមិថុនា
- ការប្រកួតជជែកដេញដោលយុវជនថ្នាក់ខេត្ត សម្រាប់ខេត្តកំពង់ចាម ក្នុងការជម្រុះជុំទី២
- ស្តង់ដាសាលារៀនគំរូក្នុងវិទ្យាល័យទាំងបីនៃស្រុកកងមាស


### សកម្មភាពធ្វើប្រេងដូងត្រជាក់របស់ប្អូនៗក្នុងក្លឹបវិទ្យាសាស្រ្ត




ពាមជីកង៖ នាព្រឹកថ្ងៃសៅរ៍ ១០រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹង ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៤ អ្នកគ្រូ ហ៊ី ចំរើន គ្រូដឹកនាំក្លឹបវិទ្យាសាស្រ្ត បានដឹកនាំសិស្សនៅក្នុងក្លឹបធ្វើប្រេងដូងត្រជាក់ដើម្បីឱ្យសិស្សនៅក្នុងក្លឹបបានយល់ដឹងពីវិធីធ្វើប្រេងដូងត្រជាក់ និងធ្វើទុកដើម្បីសម្រាប់តាំងពិព័រណ៍នៅថ្ងៃតាំងពិព័រណ៍ស្នាដៃសិស្សផងដែរ។














# កម្មវិធីឈ្វេងយល់ពីជំនាញស្ទែម



កម្មវិធីឈ្វេងយល់ពីជំនាញស្ទែម✨ក្រុមការងារ STEMUNITY
បានរៀបចំឡើងនៅ វិទ្យាល័យ ហ៊ុន សែន ពាមជីកង កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ នេះ។ សិក្ខាសាលា ក្រុមការងារ STEMUNITY (ស្ទែមយូនីធី) នឹងផ្តល់អាហារូបករណ៍ 100% ចំនួន ១៥នាក់ និង អាហារូបករណ៍ 75% ចំនួន ១៥នាក់ ទៅកាន់ប្អូនៗនៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង ដែលកំពុងរៀនថ្នាក់ទី១០, ១១ ឬ ១២។











# កម្លាំងជំនាញ នៃអធិការដ្ឋាននគរបាលស្រុកកងមាស បានបន្តវិធានការចុះផ្សព្វផ្សាយ ស្ដីពី ច្បាប់ចរាចរណ៍ផ្លូវគោក, ច្បាប់គ្រឿងញៀន វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបក្មេងទំនើង ដល់សិស្សានុសិស្ស



ពាមជីកង៖ នៅព្រឹកថ្ងៃចន្ទ ១១កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹង ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤ កម្លាំងជំនាញ នៃអធិការដ្ឋាននគរបាលស្រុកកងមាស បានបន្តវិធានការចុះផ្សព្វផ្សាយស្ដីពី ច្បាប់ចរាចរណ៍ផ្លូវគោក, ច្បាប់គ្រឿងញៀន វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបក្មេងទំនើង ដល់សិស្សានុសិស្ស នៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង ដែលនៅក្នុងនោះមានការចូលរួមពីកម្លាំងជំនាញពាក់ព័ន្ធ នាយក នាយករង លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សសរុបចំនួន ១៥៧០នាក់ ស្រីចំនួន ៧៧៥នាក់ ។

ក្នុងពិធីផ្សព្វផ្សាយច្បាប់នោះដែរ កម្លាំងជំនាញក៏បានចែកជូននៅឯកសារពាក់ព័ន្ធនិងច្បាប់មួយចំនួនផងដែរ។









# ប្រឡងប្រចាំខែមិថុនា

ពាមជីកង៖ នៅថ្ងៃពុធ ១៣កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹង ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ វិទ្យាល័យ ហ៊ុន សែន ពាមជីកង បានរៀបចំការប្រឡងប្រចាំខែមិថុនា ដល់សិស្សានុសិស្សគ្រប់កម្រិតថ្នាក់សម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤ នៅតាមអគារនីមួយៗដោយភាពតឹងរឹងបំផុត ហើយនៅតាមបន្ទប់ប្រឡងមានគណៈកម្មការអនុរក្សចំនួនពីរនាក់ និងនៅតាមអគារនីមួយៗមានគណៈកម្មការត្រួតពិនិត្យអគារមួយនាក់។ សិស្សានុសិស្សបានខិតខំយ៉ាងយកចិត្តទុកដាក់ក្នុងការប្រឡងលើវិញ្ញាសានីមួយៗ និងពោរពេញដោយក្តីសង្ឃឹម និងទន្ទឹងរង់ចាំមើលលទ្ធផលប្រឡងរបស់ខ្លួន។ ការប្រឡងប្រព្រឹត្តទៅយ៉ាងល្អ សិស្សានុសិស្សគ្រប់កម្រិតថ្នាក់បានគោរពនូវបញ្ញត្តិក្នុងពេលប្រឡងបានយ៉ាងខ្ជាប់ខ្ជួន។













# ការប្រកួតជជែកដេញដោលយុវជនថ្នាក់ខេត្ត សម្រាប់ខេត្តកំពង់ចាម ក្នុងការជម្រុះជុំទី២



អបអរសាទរ👏 ប្អូនៗវិទ្យាល័យ ហ៊ុន សែន ពាមជីកង សាលារៀនជំនាន់ថ្មី ដែលទទួលបានជ័យជំនះ ពីការប្រកួតជជែកដេញដោលយុវជនថ្នាក់ខេត្ត សម្រាប់ខេត្តកំពង់ចាម ក្នុងការជម្រុះជុំទី២ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ ដែលជាក្រុមស្រប ក្រោមប្រធានបទ" តម្លៃកសិផលរបស់កសិករខ្មែរធ្លាក់ចុះ បណ្តាលមកពីការបណ្តោយឲ្យមានចំណូលកសិផលបរទេសច្រើនលើសលប់ពេក" និងអាចឈានទៅដល់វគ្គបន្តទៀត។
សង្ឃឹមថាប្អូនៗនឹងធ្វើបានល្អប្រសើជាងនេះទៀត នៅវគ្គបន្ទាប់👍🫶🥰
ក្លឹបជជែកដេញដោល វិទ្យាល័យហ៊ុនសែនពាមជីកង





# ស្តង់ដាសាលារៀនគំរូក្នុងវិទ្យាល័យទាំងបីនៃស្រុកកងមាស



ពាមជីកង ៖ នៅព្រឹកថ្ងៃសៅរ៍ ៨រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹង ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤ ឯកឧត្តមបណ្ឌិត អ៊ុម រម្យណី រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំស្ដីពី “ស្តង់ដាសាលារៀនគំរូ ដើម្បីជំរុញវិទ្យាល័យទាំងអស់ក្នុងស្រុកកងមាសជាសាលារៀនគំរូនាពេលខាងមុខ” ដោយមានការចូលរួមពីសំណាក់ក្រុមការងារថ្នាក់ជាតិចុះជួយឃុំទាំង១១ លោកប្រធានមន្ទីរ លោកស្រីប្រធានការិយាល័យ លោក-លោកស្រីមេឃុំទាំង១១ លោកនាយកវិទ្យាល័យទាំង៣ និងលោកគ្រូអ្នកគ្រូមុខវិជ្ជាសាស្ត្រនៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង។ គោលដៅចម្បងនៃកិច្ចប្រជុំនេះ គឺដើម្បីពិនិត្យមើលវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តស្តង់ដាសាលារៀនគំរូសម្រាប់វិទ្យាល័យទាំង៣ ជាពិសេសឯកឧត្តមបណ្ឌិតបានផ្តល់នូវការពន្យល់ បកស្រាយ និងអនុវត្តស្តង់ដាសាលារៀនគំរូ ដើម្បីឱ្យទទួលបានលទ្ធផលកាន់តែប្រសើរឡើង ជាពិសេសជាប់ជាសាលាគំរូទទួលបានពានរង្វាន់ក្នុងឆ្នាំសិក្សា២០២៣-២០២៤ ខាងមុខនេះ។ ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តមបណ្ឌិតរដ្ឋលេខាធិការ បានបញ្ជាក់ថា ក្រសួងអប់រំ យុវជន និងកីឡា បានចេញប្រកាសដាក់ឱ្យអនុវត្តស្តង់ដាសាលារៀនគំរូដែលមានលក្ខណៈសម្បត្តិដូចតទៅ៖ ទី១- សាលារៀនមានគណនេយ្យភាពជាមួយសហគមន៍ និងសម្រេចបានស្តង់ដាសាលារៀនគំរូ, ទី២- សាលារៀនមានស្វ័យភាពក្នុងការងារផែនការកែលម្អសាលារៀន ផែនការកែលម្អថ្នាក់រៀន និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន, ទី៣- សិស្សត្រូវបានធ្វើតេស្តស្តង់ដាប្រកបដោយតម្លាភាព និងយុត្តិធម៌ ដើម្បីបម្រើដល់ការកែលម្អការបង្រៀននិងរៀន ការជួយសិស្សរៀនយឺត និងផ្តល់ព័ត៌មានដល់មាតាបិតា ឬអ្នកអាណាព្យាបាល និងសហគមន៍, ទី៤- គ្រូបង្រៀនប្រើប្រាស់លទ្ធផលតេស្ត ដើម្បីកែលម្អការបង្រៀន និងទទួលបានការអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំ, ទី៥- ការបង្កើតសកម្មភាពក្រៅម៉ោងសិក្សា ដើម្បីការអប់រំចរិយាធម៌ និងសីលធម៌, ទី៦- ការយកចិត្តទុកដាក់ដល់សុខភាពសិក្សា និងទី៧- ការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ ក្នុងការគាំទ្រ និងអភិវឌ្ឍសាលារៀន។

ជាចុងក្រោយ ឯកឧត្តមបណ្ឌិតរដ្ឋលេខាធិការបាននាំយកនូវសៀវភៅកម្រងវិញ្ញាសាធ្លាប់ចេញប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដើម្បីប្រគល់ជូនលោកនាយកវិទ្យាល័យទាំងបីផងដែរ។